ក្រសួងមុខងារសាធារណៈ
MINISTRY OF CIVIL SERVICE

# ការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការ

ឱ្យចូលបម្រើការងារនៅ

# មន្ទីរពេទ្យបង្អែកកម្រិត ១ ពាក់ស្នែង

សូមស្កេនដើម្បីបំពេញព័ត៌មានសុំសិទ្ធិប្រឡងប្រជែង

https://go.gou.kh/era/mospaksneng24

ប្រព័ន្ធនឹងចាប់ផ្ដើមបើកពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៤ ដល់ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៤ វេលាម៉ោង ១៧:០០ ជាកំហិត។

គុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាបន្ន និងប្រសិទ្ធភាព

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ : ៤៧១៩/២៤ មស.នភស

# សេចក្តីជូនដំណឹង
## ស្តីពី
## ការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការ ឱ្យចូលបម្រើការងារនៅ
## មន្ទីរពេទ្យបង្អែកកម្រិត១ ពាក់ស្វែង

**យោង** ៖- អនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការដាក់ឱ្យអនុវត្តនិយាមនីតិវិធីប្រតិបត្តិសម្រាប់ការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិល

- លិខិតលេខ ១៣០៩/២៤ មស.ន.កវស ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៤ របស់ក្រសួងមុខងារសាធារណៈ
- ចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២៤ លើលិខិតលេខ ៤៥១៤/២៤ មស.ន.កវស របស់ក្រសួងមុខងារសាធារណៈ។

គណៈកម្មការរៀបចំការប្រឡងប្រជែង សូមជូនដំណឹងដល់សិស្ស និស្សិត និងសាធារណជន ឱ្យបានជ្រាបថា គណៈកម្មការនឹងរៀបចំការប្រឡងប្រជែងជ្រើសរើសក្របខណ្ឌមន្ត្រីរាជការចំនួន **៤៦កន្លែង** ឱ្យចូលបម្រើការងារនៅមន្ទីរពេទ្យបង្អែកកម្រិត១ ពាក់ស្វែង នៃរដ្ឋបាលខេត្តសៀមរាប ដូចខាងក្រោម៖

| ល.រ | មុខតំណែងជ្រើសរើស | គុណវុឌ្ឍិ | ក្របខណ្ឌជ្រើសរើស | |
|---|---|---|---|---|
| | | | ក | ខ |
| ១ | វេជ្ជបណ្ឌិត | សញ្ញាបត្រវេជ្ជបណ្ឌិតទូទៅ | ៦ | |
| ២ | ឱសថការី | សញ្ញាបត្រឱសថការី | ២ | |
| ៣ | ទន្តបណ្ឌិត | សញ្ញាបត្រទន្តបណ្ឌិតទូទៅ | ១ | |
| ៤ | គិលានុបដ្ឋាក | សញ្ញាបត្រគិលានុបដ្ឋាក | ២ | |
| ៥ | ឆ្មប | សញ្ញាបត្រឆ្មប | ៣ | |
| ៦ | មន្ត្រីព័ត៌មានវិទ្យា | បរិញ្ញាបត្រព័ត៌មានវិទ្យា | ១ | |
| ៧ | មន្ត្រីគណនេយ្យ | បរិញ្ញាបត្រគណនេយ្យ /ហិរញ្ញវត្ថុ /ធនាគារ /សេដ្ឋកិច្ច | ២ | |
| ៨ | គិលានុបដ្ឋាកមធ្យម | បរិញ្ញាបត្ររងគិលានុបដ្ឋាក | | ១៥ |
| ៩ | ទន្តគិលានុបដ្ឋាក | បរិញ្ញាបត្ររងទន្តគិលានុបដ្ឋាក | | ១ |
| ១០ | ឆ្មបមធ្យម | បរិញ្ញាបត្ររងឆ្មប | | ៧ |
| ១១ | អ្នកបច្ចេកទេសវិទ្យុសាស្ត្រ | បរិញ្ញាបត្ររងបច្ចេកទេសវិទ្យុសាស្ត្រ | | ១ |
| ១២ | អ្នកបច្ចេកទេសមន្ទីរពិសោធន៍មធ្យម | បរិញ្ញាបត្ររងបច្ចេកទេសមន្ទីរពិសោធន៍ | | ៣ |
| ១៣ | មន្ត្រីរដ្ឋបាល | បរិញ្ញាបត្ររងរដ្ឋបាលសាធារណៈ /គ្រប់គ្រងទូទៅ /គ្រប់គ្រងធនធានមនុស្ស | | ២ |
| សរុប | | | ១៧ | ២៩ |
| | | | ៤៦ | |



០៦៩៨

ផ្លូវវត្តអង្គតាមិញ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ កម្ពុជា
St. Watangtaminh, Sangkat Chomchoa, Khan Posenchey, Phnom Penh, CAMBODIA
ទូរស័ព្ទ : (+៨៥៥) ២៣ ៨៦៦ ៥០១
Phone : (+855) 23 866 501
www.mcs.gov.kh

**ក. លក្ខខណ្ឌនៃការជ្រើសរើស**

១. បេក្ខជនត្រូវមានសញ្ជាតិខ្មែរ

២. បេក្ខជនត្រូវមានកម្រិតសញ្ញាបត្រ៖

- ចាប់ពីបរិញ្ញាបត្រ ឬសញ្ញាបត្រសមមូលឡើងទៅ សម្រាប់ប្រភេទក្របខណ្ឌ "**ក**"
- ចាប់ពីបរិញ្ញាបត្ររង ឬសញ្ញាបត្រសមមូលឡើងទៅ សម្រាប់ប្រភេទក្របខណ្ឌ "**ខ**"។

៣. បេក្ខជនត្រូវមានអាយុយ៉ាងតិច១៨ឆ្នាំ និងអាយុយ៉ាងច្រើនបំផុត គិតត្រឹមថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៤ តាមលក្ខខណ្ឌខាងក្រោម៖

- បេក្ខជនជាមន្ត្រីរាជការ ត្រូវបានលើកលែងលក្ខខណ្ឌអាយុ
- បេក្ខជនមានសញ្ញាបត្របណ្ឌិត ត្រូវបានលើកលែងលក្ខខណ្ឌអាយុ
- បេក្ខជនជាសិស្សនិងនិស្សិតដែលមានសញ្ញាបត្រផ្នែកវេជ្ជសាស្ត្រ ផ្នែកឱសថសាស្ត្រ ផ្នែកទន្តវេទសាស្ត្រ ឬវិទ្យាសាស្ត្រសុខាភិបាល នឹងត្រូវលើកលែងលក្ខខណ្ឌអាយុសម្រាប់ការចូលរួមប្រឡងប្រជែងជ្រើសរើសចូលបម្រើការងារក្នុងក្របខណ្ឌមន្ត្រីរាជការស៊ីវិលក្នុងមុខតំណែងវិជ្ជាជីវៈសុខាភិបាល
- បេក្ខជនមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ឬសញ្ញាបត្រសមមូល ត្រូវមានអាយុច្រើនបំផុត ៤០ឆ្នាំ
- បេក្ខជនមានសញ្ញាបត្របរិញ្ញាបត្រ ឬសញ្ញាបត្រសមមូល ត្រូវមានអាយុច្រើនបំផុត ៣៥ឆ្នាំ
- បេក្ខជនមានសញ្ញាបត្របរិញ្ញាបត្ររង ឬសញ្ញាបត្រសមមូល ត្រូវមានអាយុច្រើនបំផុត ២៨ឆ្នាំ។

៤. បេក្ខជនមិនត្រូវប្រាសចាកសិទ្ធិខាងផ្លូវរដ្ឋប្បវេណី សិទ្ធិពលរដ្ឋ និងសិទ្ធិខាងនយោបាយ

៥. ការលើកទឹកចិត្ត និងការផ្តល់អាទិភាព៖

- ជនមានពិការភាពដែលមានគុណសម្បត្តិ និងសមត្ថភាពបំពេញនូវមុខងារ តួនាទី និងការទទួលខុសត្រូវក្នុងមុខតំណែងដែលបានដាក់ពាក្យ
- ជនជាតិដើមភាគតិច
- ស្ត្រី
- មន្ត្រីជាប់កិច្ចសន្យាដែលបម្រើការងារក្នុងរដ្ឋបាលសាធារណៈ
- បេក្ខជនមានអាយុច្រើនជាងគេ។

**ខ. កាលបរិច្ឆេទចុះឈ្មោះប្រឡងប្រជែង និងការដាក់ពាក្យ**

១. **កាលបរិច្ឆេទចុះឈ្មោះប្រឡងប្រជែង៖ ចាប់ពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៤ រហូតដល់ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២៤ វេលាម៉ោង ១៧:០០ ជាកំហិត។**

២. **ការដាក់ពាក្យប្រឡងប្រជែងតាមរយៈប្រព័ន្ធអនឡាញ៖**

- បេក្ខជនអាចស្កេន QR Code ខាងក្រោម ឬចូលទៅកាន់គេហទំព័រ https://go.gov.kh/era/mcspaksneng24 ដើម្បីបំពេញព័ត៌មានសុំសិទ្ធិប្រឡងប្រជែង និងស្កេនបញ្ចូលឯកសារតម្រូវសម្រាប់ការដាក់ពាក្យ
- បេក្ខជនត្រូវប្រើប្រាស់**លេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ** សម្រាប់ការចុះឈ្មោះតាមប្រព័ន្ធអនឡាញ។ ក្នុងករណីមិនមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ បេក្ខជនត្រូវធ្វើការទំនាក់ទំនងជាមួយមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត ដើម្បីជួយសម្រួលការចុះឈ្មោះ។

៣. **ឯកសារតម្រូវ ត្រូវស្កេនពីឯកសារដើម ឬពីឯកសារមានបញ្ជាក់ផ្លូវការ៖**

- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ។ ក្នុងករណីមិនមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ បេក្ខជនត្រូវទំនាក់ទំនងជាមួយមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត ដើម្បីជួយសម្របសម្រួលបំពេញបែបបទ
- សញ្ញាបត្រ ឬវិញ្ញាបនបត្របណ្តោះអាសន្ន ឬសញ្ញាបត្រសមមូល តាមលក្ខខណ្ឌជ្រើសរើសខាងលើ



២៤៥៨

បញ្ជាក់៖

- ចំពោះសញ្ញាបត្រសិក្សាក្នុងស្រុក ជាភាសាបរទេសត្រូវបញ្ជាក់ជាភាសាជាតិ នៅគ្រឹះស្ថានសិក្សារបស់ខ្លួន
- ចំពោះសញ្ញាបត្រសិក្សានៅបរទេស ត្រូវបញ្ជាក់ពីកម្រិតសញ្ញាបត្រជាភាសាជាតិ ដោយមានការទទួលស្គាល់ពីក្រសួងសុខាភិបាល ឬក្រសួងអប់រំ យុវជន និងកីឡា។

- រូបថតចំពីមុខ គ្មានពាក់មួក គ្មានពាក់វ៉ែនតា ទំហំ ៤x៦ (ផ្ទៃខាងក្រោយពណ៌ស ឬផ្ទៃមេឃ) ថតថ្មី ៦ខែចុងក្រោយ
- ចំពោះមន្ត្រីរាជការ ត្រូវមានលិខិតអនុញ្ញាតឱ្យចូលរួមប្រឡងប្រជែងចេញដោយប្រធានស្ថាប័ន ឬអាជ្ញាធរ ដែលមានសិទ្ធិអនុញ្ញាតឱ្យផ្ទេរ(មានគំរូជូនភ្ជាប់)។

**សម្គាល់៖** នៅពេលប្រឡងប្រជែងជាប់ជាស្ថាពរ បេក្ខជនត្រូវផ្តល់ឯកសារពាក់ព័ន្ធ ដើម្បីធ្វើការពិនិត្យ និងផ្ទៀងផ្ទាត់ដូចខាងក្រោម៖

| | |
|---|---|
| - សេចក្តីចម្លងសញ្ញាបត្រ ឬវិញ្ញាបនបត្រ (បញ្ជាក់ផ្លូវការ) | ចំនួន ០១ច្បាប់ |
| - សេចក្តីចម្លងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ (បញ្ជាក់ផ្លូវការ) | ចំនួន ០១ច្បាប់ |
| - សេចក្តីចម្លងសំបុត្រកំណើត ឬបញ្ជាក់កំណើត | ចំនួន ០១ច្បាប់ |
| - លិខិតអនុញ្ញាតឱ្យចូលរួមការប្រឡងប្រជែងរបស់ក្រសួង ស្ថាប័ន ឬអាជ្ញាធរ (សម្រាប់បេក្ខជនជាមន្ត្រីរាជការ) | ចំនួន ០១ច្បាប់ |
| - សេចក្តីចម្លងសៀវភៅស្នាក់នៅ ឬ សៀវភៅគ្រួសារ (បញ្ជាក់ផ្លូវការ) | ចំនួន ០១ច្បាប់ |
| - លិខិតថ្កោលទោស (សម្រាប់បេក្ខជនជានិស្សិត) | ចំនួន ០១ច្បាប់ |
| - វិញ្ញាបនបត្របញ្ជាក់សុខភាព និងសារជាតុញៀន (សម្រាប់បេក្ខជនជានិស្សិត) | ចំនួន ០១ច្បាប់ |
| - រូបថតចំពីមុខ គ្មានពាក់មួក គ្មានពាក់វ៉ែនតា ទំហំ ៤x៦ | ចំនួន ០៤សន្លឹក។ |

## គ. លក្ខខណ្ឌគតិយុត្ត និងគោលការណ៍ផ្សេងៗ

១. បេក្ខជនដែលបានប្រឡងជាប់ជាស្ថាពរ មិនត្រូវបានអនុញ្ញាតឱ្យផ្លាស់ប្តូរកន្លែងបំពេញការងារដោយហេតុផលណាមួយឡើយ។ ការផ្លាស់ប្តូរកន្លែងបំពេញការងារ មានន័យថាសាមីជននោះបោះបង់ក្របខណ្ឌមន្ត្រីរាជការ។ ការផ្លាស់ប្តូរកន្លែងបំពេញការងារ អាចធ្វើទៅបានក្នុងករណីមានការសម្រេចពីរាជរដ្ឋាភិបាល ក្នុងការចាត់ចែងការប្រើប្រាស់មន្ត្រីរាជការផ្អែកលើការចាំបាច់

២. ករណីរកឃើញមានការក្លែងបន្លំសញ្ញាបត្រ ឬវិញ្ញាបនបត្រ ឬលិខិតស្នាមផ្សេងៗ បេក្ខជននឹងត្រូវលុបឈ្មោះចេញជាស្វ័យប្រវត្តិ ទោះបីជាបេក្ខជននោះ បានប្រឡងប្រជែងជាប់ជាស្ថាពរក៏ដោយ និងត្រូវប្រឈមចំពោះមុខច្បាប់ជាធរមាន

៣. បេក្ខសមណៈ(ជាបព្វជិត ឬព្រះសង្ឃ) មានមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៅអគ្គាធិការដ្ឋានពុទ្ធិកសិក្សា នៃក្រសួងធម្មការ និងសាសនា នៅពេលប្រឡងប្រជែងជាប់ជាស្ថាពរ គឺតម្រូវឱ្យលាចាកសិក្ខាបទ និង មិនរក្សាបានមុខតំណែងឡើយ

៤. បេក្ខជនជាមន្ត្រីរាជការ ក្រោយពេលប្រឡងប្រជែងជាប់ជាស្ថាពរ ត្រូវរក្សាអតីតភាពការងារ ប៉ុន្តែមិនរក្សាមុខតំណែងគ្រប់គ្រងទេ និងត្រូវរៀបចំផ្ទេរបៀវត្សទៅកាន់អង្គភាពថ្មី។

## ឃ. វិញ្ញាសាប្រឡងប្រជែង

| | | | |
|---|---|---|---|
| ១. វិញ្ញាសាសរសេរ | ៖ ជំនាញ/ឯកទេស | រយៈពេល ២ម៉ោង | ១០០ពិន្ទុ មេគុណ ២ |
| ២. វិញ្ញាសាពហុចម្លើយ | ៖ ភាសាបរទេស(អង់គ្លេស ឬបារាំង) | រយៈពេល ១ម៉ោង | ៥០ពិន្ទុ មេគុណ ១ |
| ៣. វិញ្ញាសាពហុចម្លើយ | ៖ ចំណេះដឹងទូទៅ | រយៈពេល ១ម៉ោង | ១០០ពិន្ទុ មេគុណ ១ |

**សម្គាល់៖** ចំណេះដឹងទូទៅពាក់ព័ន្ធនឹង(១)មុខងារសាធារណៈ ក្រមសីលធម៌វិជ្ជាជីវៈ គោលនយោបាយរបស់រាជរដ្ឋាភិបាល រដ្ឋបាលសាធារណៈ វប្បធម៌ទូទៅ ពលរដ្ឋវិទ្យា ប្រវត្តិសាស្ត្រកម្ពុជា ភូមិសាស្ត្រកម្ពុជា អាស៊ាន និងសេដ្ឋកិច្ចកម្ពុជា (សរុប ៥០ពិន្ទុ) និង(២)ចំណេះដឹងពាក់ព័ន្ធជំនាញ/ឯកទេស (សរុប ៥០ពិន្ទុ)។

## ខ. សម័យប្រឡង និងមណ្ឌលប្រឡង

**១. សម័យប្រឡង៖** ជូនដំណឹងពេលក្រោយ

**២. មណ្ឌលប្រឡង៖** នៅរាជធានីភ្នំពេញ (ទីតាំងមណ្ឌលប្រឡង នឹងជូនដំណឹងពេលក្រោយ)។

☞ **បញ្ជាក់ ៖**

១. ចំពោះបេក្ខជនដែលបានចុះឈ្មោះរួចរាល់ សូមចូលទៅពិនិត្យមើលសារឆ្លើយតបក្នុងប្រព័ន្ធចុះឈ្មោះអនឡាញតាមរយៈតំណភ្ជាប់ **https://go.gov.kh/era/mcspaksneng24** ឬអ៊ីម៉ែលសាមីខ្លួនដើម្បីបំពេញលក្ខខណ្ឌបន្ត បន្ទាប់ពីក្រុមការងារបានពិនិត្យ និងផ្ទៀតផ្ទាត់ព័ត៌មានតម្រូវរួចរាល់។ បេក្ខជនត្រូវប្រើប្រាស់ព័ត៌មានផ្លូវការដែលផ្តល់ដោយប្រព័ន្ធចុះឈ្មោះដែលគ្រប់គ្រងដោយក្រសួងមុខងារសាធារណៈតែប៉ុណ្ណោះ។

២. ចំពោះព័ត៌មានពាក់ព័ន្ធនឹងប្រព័ន្ធចុះឈ្មោះតាមអនឡាញ សូមទំនាក់ទំនងតាមទូរស័ព្ទ និងប្រព័ន្ធ **Telegram** ០១០ ៤៣៧ ៩២២, ០៩៨ ៥៥២ ៥៧៧, ០១០ ៤១៦ ៥៧៣, ០៦១ ២៦៨ ៩៩៩ និង ០៩៦ ៩៣៣ ៣៤៤១ រៀងរាល់ម៉ោងធ្វើការ។

៣. គណៈកម្មការរៀបចំការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការ សូមរក្សាសិទ្ធិកែប្រែក្នុងករណីចាំបាច់។

ថ្ងៃ ចន្ទ ៣រោច ខែ កត្តិក ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជាប្រធាន**

**គណៈកម្មការរៀបចំការប្រឡងប្រជែង**

ហ៊ុន_ម៉ានី

សូមស្កេនដើម្បីបំពេញព័ត៌មានសុំសិទ្ធិប្រឡងប្រជែង

**ចម្លងជូន៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- ក្រសួងសុខាភិបាល
- រដ្ឋបាលខេត្តសៀមរាប
- មន្ទីរមុខងារសាធារណៈខេត្តសៀមរាប
- មន្ទីរសុខាភិបាលខេត្តសៀមរាប
  "ដើម្បីសហការអនុវត្ត"
- ឯកសារ កាលប្បវត្តិ